# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Feb-2013, 13:45
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៣

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកឯកសារនានា ដែលមាននៅ E190.1 និង E190.2.1**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | សហព្រះរាជអាជ្ញា |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | លោកស្រី ជា លាង |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោក Andrew CAYLEY |
| លោក Michael G. KARNAVAS | ចៅក្រម យូ ឧត្តរា | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម យ៉ា សុខន | **ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់** |
| | ចៅក្រម Silvia CARTWRIGHT | |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង ធូ មណី | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមតាមវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ(“វិធានផ្ទៃក្នុង”) តទៅនេះសូមធ្វើការបញ្ជាក់ពីការជំទាស់របស់គាត់ដែលដាក់ភ្ជាប់ជាមួយឧបសម្ព័ន្ធ ទៅនឹងការទទួលយកឯកសារនានាដែលមាននៅក្នុង E190.1 ។ ឯកសារដែលត្រូវបានផ្តល់លេខ E3 មិនត្រូវបានដាក់បញ្ចូល ដោយសារមានឯកសារមួយចំនួនមាននៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា E223/2/1.1[1] ដោយសារឯកសារទាំងនេះជាប្រធានបទនៃការជំទាស់ផ្សេងទៀតនាពេលថ្មីៗនេះ[2] ។ សេចក្តីជំទាស់ទៅនឹងឯកសារចម្លើយសាក្សីមួយចំនួនដែលស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុង E190.1 ត្រូវបានដាក់បញ្ចូល បើទោះបីវាហាក់ដូចជាថា ដើមបណ្តឹងរដ្ឋប្បវេណីលែងស្នើឲ្យទទួលយកឯកសារចម្លើយសាក្សីទាំងនេះជាភស្តុតាងតទៅទៀតហើយក្តី[3]។ ការជំទាស់ក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយនេះត្រូវបានដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីជួយអង្គជំនុំជម្រះក្នុងការសម្រេចពីភាពអាចទទួលយកបាននៃឯកសារជាក់លាក់មួយចំនួនជាភស្តុតាងនៅចំពោះមុខខ្លួនក្នុងសំណុំរឿង០០២។ មេធាវីការពារក្តីមិនអាចជំទាស់ទៅនឹងឯកសារដោយឈរលើមូលដ្ឋាននៃភាពពាក់ព័ន្ធបានឡើយ ព្រោះវិសាលភាពនៃការជំនុំជម្រះមិនត្រូវបានគេដឹងនៅឡើយនាពេលបច្ចុប្បន្ននេះ។ ឯកសារជាច្រើនដែលមានក្នុងឯកសារ E190.1 ហាក់ដូចជា *មិន*ពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះ ដែលបានកំណត់យ៉ាងច្បាស់ក្នុងដីកាបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង[4]ឡើយ។ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចមិនជំនុំជម្រះករណី០០២ទាំងមូល

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យបញ្ជាក់ឯកសារបន្ថែមដែលពាក់ព័ន្ធចំពោះការជន្លៀសប្រជាជន និង វគ្គនៃការជំនុំជម្រះទាក់ទងនឹងទួលពោធិ៍ជ្រៃ និង សំណើសុំការកំណត់កាលបរិច្ឆេទ សវនាការលើឯកសារចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ E223/2/1, ឧបសម្ព័ន្ធ E223/2/1.1 ។

[2] សូមមើលការជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកឯកសារជាក់លាក់មួយចំនួន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ E223/2/2 ឧបសម្ព័ន្ធ E223/2/2/4 ។

[3] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងនេះត្រូវបានដាក់នៅក្នុងបញ្ជីឯកសារដំបូងរបស់ដើមបណ្តឹងរដ្ឋប្បវេណី (E109/2.3) នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនលើសារណាអនុលោមតាមវិធាន ៩២ របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការទទួលយកជាភស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងឯកសារដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង E96/7 ដោយតម្រូវឲ្យភាគីពិនិត្យឡើងវិញលើឯកសារនៅក្នុងបញ្ជីរបស់ខ្លួនឲ្យស្របតាមសេចក្តីសម្រេចរបស់ខ្លួន ដើម្បីបញ្ជាក់ពីគោលបំណងជាភស្តុតាងនៃឯកសារនិមួយៗ និងដើម្បីផ្តល់លក្ខណៈពិសេសមិនឲ្យហួសពីថ្ងៃទី២៧ ខែកក្កដាឆ្នាំ២០១២។ ប៉ុន្តែដើមបណ្តឹងតរដ្ឋប្បវេណីមិនបានធ្វើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទេ តែបានដាក់សារណាបន្ថែមទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅវិញ (សូមមើល E208/4), មិនមែនជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទេ។

[4] ដីកាបំបែកសំណុំរឿង អនុលោមតាមវិធានផ្ទៃក្នុង៨៩ *ស្ទួន*, ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១, E124។

មេធាវីការពារក្តីសូមស្នើសុំឱកាសដើម្បីដាក់សារណាបន្ថែមទៀតពាក់ព័ន្ធនឹងភាពពាក់ព័ន្ធ។ ចុងបញ្ចប់ ដោយសារតែមេធាវីការពារក្តីមិនមានកាតព្វកិច្ចវាយតម្លៃយថាភូតនៃឯកសារទាំងនោះ មេធាវីការពារក្តីសូមជំទាស់ទៅនឹងការទទួលយកឯកសារនានា ដែលមិនបង្ហាញពីយថាភូតច្បាស់លាស់ ឬ មិនត្រូវបានបង្ហាញថាមានយថាភូតដោយភាគីដែលស្នើដាក់ឯកសារនោះ។

សម្រាប់មូលហេតុដែលបានលើកឡើងក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ មេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូង **បដិសេធ**ចោលឯកសារដែលមេធាវីការពារក្តីបានជំទាស់ក្នុងសេចក្តីជំទាស់របស់ខ្លួន។

សូមលោក/លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលយកសំណើនេះដោយគោរព ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២២** ខែ **កុម្ភៈ** ឆ្នាំ **២០១៣**

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**